ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការចាត់ថ្នាក់ផ្ទៃដីព្រៃលិចទឹក ការធ្វើអនុបយោគ និងការប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ ស្ថិតក្នុងសង្កាត់រាម និងសង្កាត់បិតត្រាំង ខណ្ឌព្រៃនុប ក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញប្រកាសលេខ ០០៦៧ បក កសក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៨៩ ស្តីពីការកំណត់នាទីព្រៃលិចទឹកនៅទឹកសាប និងសមុទ្រ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១ :** ត្រូវបានចាត់ថ្នាក់ផ្ទៃដីព្រៃលិចទឹក ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងក្រៅពីវិស័យជលផល ទំហំពីររយសាមសិបប្រាំពីរហិកតា (២៣៧ ហ.ត) ស្ថិតនៅសង្កាត់រាម និងសង្កាត់បិតត្រាំង ខណ្ឌព្រៃនុប ក្រុងព្រះសីហនុ ដែលមាននិយាមការ :

**តំបន់ទី១ :**

**1** : 350969, 1168051
**2** : 350374, 1167064
**3** : 350093, 1166650
**4** : 349959, 1166399
**5** : 349950, 1165990
**6** : 349326, 1165988
**7** : 349171, 1166500
**8** : 350720, 1169387
**9** : 350771, 1169327
**10** : 350758, 1169269
**11** : 350682, 1169171
**12** : 350625, 1169076
**13**: 350513, 1168873
**14** : 350618, 1168792
**15** : 350692, 1168751
**16** :350701, 1168694
**17** : 350610, 1168652
**18** : 350561, 1168537
**19** : 350555, 1168497
**20** : 350554, 1168496
**21** : 350469, 1168306
**22** : 355969, 1168051

**តំបន់ទី២ :**

**1** : 350292, 1169749
**2** : 350347, 1169771
**3** : 350413, 1169747
**4** : 350462, 1169681
**5** : 350503, 1169722
**6** : 350692, 1169928
**7** : 350799, 1170051
**8** : 350782, 1170117
**9** : 350717, 1170183
**10** : 350676, 1170215
**11** : 350725, 1170298
**12** : 350807, 1170232
**13** : 350906, 1170215
**14** : 350997, 1170347
**15** : 351095, 1170322
**16** : 351128, 1170257
**17** : 351063, 1170158
**18** : 350980, 1170125
**19** : 350890, 1169993
**20** : 351120, 1169829
**21** : 351071, 1169796
**22** : 350840, 1169837
**23** : 350783, 1169837
**24** : 350618, 1169582
**25** : 350690, 1169504
**26** : 350688, 1169504
**27** : 350292, 1169749

**មាត្រា ២ :** ត្រូវបានផ្ទេរផ្ទៃដីព្រៃលិចទឹក ទំហំពីររយសាមសិបប្រាំពីរហិកតា (២៣៧ ហ.ត) ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែននេសាទ ដើម្បីគោលបំណងអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិកងកេង ។

**មាត្រា ៣ :** ត្រូវបានធ្វើអនុបយោគផ្ទៃដីព្រៃលិចទឹក ទំហំពីររយសាមសិបប្រាំពីរហិកតា (២៣៧ ហ.ត) ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។ ផែនទីបញ្ជាក់ទីតាំង ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៤ :** ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ ជូនរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ទំហំពីររយសាមសិបប្រាំពីរហិកតា (២៣៧ ហិកតា ) ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះសម្រាប់គោលដៅអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិកងកេង ។

**មាត្រា ៥ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋលេខាធិការអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ ✓